ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMICS


# ឯកសារស្តីពីការដេញថ្លៃប្រកួតប្រជែងជាសាធារណៈលើការផ្តល់សេវាកម្មផ្ញើកង់ ម៉ូតូ និងរថយន្ត នៅ ស.ភ.ន.វ.ស

តំណាងរូបវន្តបុគ្គល ឬតំណាងចូលរួម៖ ..........................................................................................

អាសយដ្ឋានទំនាក់ទំនង ៖ ..........................................................................................

ទូរស័ព្ទ ៖ ..........................................................................................

កាលបរិច្ឆេទចាប់លក់ពាក្យ ៖នៅម៉ោង ៧... និង ៣០ នាទី ថ្ងៃទី២៧ខែសីហាឆ្នាំ២០១៥

កាលបរិច្ឆេទឈប់ទទួលពាក្យ ៖នៅម៉ោង .៨... និង ៣០ នាទី ថ្ងៃទី១៥ខែកញ្ញាឆ្នាំ២០១៥

កាលបរិច្ឆេទបើកឯកសារដេញថ្លៃ ៖នៅម៉ោង .៨... និង ៣០ នាទី ថ្ងៃទី១៦ខែកញ្ញាឆ្នាំ២០១៥




Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855) 23 214 953, E-mail: rector@rule.edu.kh, website: www.rule.edu.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**លេខ:** ៧៦៩ **សភនវស**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់សេវាកម្មផ្ញើ កង់ ម៉ូតូ និងរថយន្ត

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា សាកលវិទ្យាល័យនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សេវាកម្មផ្ញើ កង់ ម៉ូតូ និងរថយន្ត។

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃសាកលវិទ្យាល័យ ដែលមានអាសយដ្ឋានមហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០១៥ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ ០១៧ ៦៧៨ ៧៩៧, ០១៧ ៩៦៨ ៨៨១) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ **នៅម៉ោង** ៩:៣០ **ថ្ងៃទី** ១៥ **ខែ** កញ្ញា **ឆ្នាំ** ២០១៥ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ៩:៣០ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**បណ្ឌិត លុយ ចណ្ណា**

**ចម្លងជូន ៖**

-ក្រុមប្រឹក្សាភិបាល

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ

អាស័យដ្ឋាន: មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ, ប្រអប់សំបុត្រ ៨៤២, ទូរស័ព្ទ: (៨៥៥) ២៣ ២១ ៤៧ ០៣, ទូរសារ: (៨៥៥) ២៣ ២១ ៤៩ ៥៣

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, CAMBODIA, P.O. Box 842, Phone: (855) 23 21 47 03

Fax: (855) 23 21 49 53, E-mail: rector@rule.edu.kh, website: www.rule.edu.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមហ៊ុន.................................................
អាសយដ្ឋាន..........................................
លេខ.......................................................

## ពាក្យសុំចូលរួមដេញថ្លៃ

ខ្ញុំបាទ-នាងខ្ញុំ........................ មុខងារ.................................. ក្រុមហ៊ុន..................................
អាសយដ្ឋាន.......................................................................................................................
ទូរស័ព្ទ.......................

**សូមគោរពជូន**
**ឯកឧត្តមប្រធានគណៈកម្មាធិការលទ្ធកម្ម**

**កម្មវត្ថុ៖** សំណើសុំចូលរួមដេញថ្លៃប្រកួតប្រជែងជាសាធារណៈ លើការផ្តល់សេវាកម្មផ្ញើ កង់ ម៉ូតូ និង រថយន្ត ជូន **ស.ភ.ន.វ.ស** សម្រាប់ឆ្នាំ២០១៥។

**យោង៖** សេចក្តីជូនដំណឹងលេខ................. ចុះថ្ងៃទី.........ខែ................ឆ្នាំ២០...... ស្តីពីការដាក់ឲ្យដេញថ្លៃជាសាធារណៈនូវការផ្តល់សេវាកម្មផ្ញើ កង់ ម៉ូតូ និងរថយន្ត ជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ-នាងខ្ញុំ រីករាយនឹងដាក់តម្លៃក្នុងការផ្តល់សេវាកម្មផ្ញើ កង់ ម៉ូតូ និងរថយន្ត រយៈពេល...............ជូនសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានទឹកប្រាក់សរុបចំនួន..................(ជាអក្សរ)..................................................................................... នូវតម្លៃសរុបរួមទាំងអាករលើតម្លៃបន្ថែម (ប្រសិនបើច្បាប់តម្រូវ)។

ប្រសិនបើពាក្យសុំដេញថ្លៃ ត្រូវបានទទួលយល់ព្រមហើយ ខ្ញុំបាទ-នាងខ្ញុំ និង ចាប់ផ្តើមធ្វើការផ្តល់សេវាជូនក្នុងរយៈពេល................ថ្ងៃយ៉ាងយូរបំផុត ។

ខ្ញុំបាទ-នាងខ្ញុំយល់ព្រម និងគោរពតាមកិច្ចសន្យានៃការដេញថ្លៃនេះ សម្រាប់រយៈពេលកំណត់បើកឯកសារដេញថ្លៃប្រកួតប្រជែងជាសាធារណៈ រហូតដល់កិច្ចសន្យាត្រូវបញ្ចប់ជាស្ថាពរ ។

អាស្រ័យហេតុនេះ ខ្ញុំបាទ-នាងខ្ញុំ សូមឯកឧត្តមប្រធានគណៈកម្មាធិការលទ្ធកម្ម ចុះឈ្មោះខ្ញុំបាទ-នាងខ្ញុំ ចូលរួមក្នុងការដេញថ្លៃប្រកួតប្រជែង ជាសាធារណៈលើការផ្តល់សេវាកម្មផ្ញើ កង់ ម៉ូតូ និង រថយន្តនេះជូន **ស.ភ.ន.វ.ស** ដោយក្តីអនុគ្រោះ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.........ខែ................ឆ្នាំ.............
**ហត្ថលេខា និងត្រាអ្នកសុំដេញថ្លៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ** .............

# លិខិតធានា

# ប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម......**

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស ......................................... មានបំណងដាក់សំណើដេញថ្លៃដើម្បីធ្វើការផ្គត់ផ្គង់សេវាកម្មថ្មើ កង់ ម៉ូតូ និងរថយន្តដែលត្រូវបើកសំណើដេញថ្លៃនៅថ្ងៃទី......... ខែ........ឆ្នាំ..................។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ........... សូមធានាចំពោះមុខគណៈកម្មាធិការលទ្ធកម្ម...................... នូវប្រាក់កក់ធានាការដេញថ្លៃចំនួន ...................................... (សរសេរជាអក្សរ.....................................) ។

ក្នុងករណីមានលក្ខខណ្ឌណាមួយកើតមានឡើងក្នុងចំណោមលក្ខខណ្ឌទាំងបីខាងក្រោម ៖

១-ប្រសិនបើអ្នកដេញថ្លៃ ដកសំណើដេញថ្លៃរបស់ខ្លួន ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

២-ប្រសិនបើអ្នកដេញថ្លៃ បដិសេធការចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

៣-ប្រសិនបើអ្នកដេញថ្លៃ មិនព្រមកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ។

នោះអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ........... នឹងធ្វើការបង្វែរចូលថវិការដ្ឋនូវចំនួនប្រាក់កក់ខាងលើ នៅពេលដែលបានទទួលលិខិតស្នើសុំពីគណៈកម្មាធិការលទ្ធកម្ម ដែលបញ្ជាក់ថាអ្នកដេញថ្លៃមិនគោរពតាមលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងបីខាងលើ ។

លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាព រយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃ ក្រោយសុពលភាពសំណើដេញថ្លៃ ។

................ ថ្ងៃទី............. ខែ ............. ឆ្នាំ.............

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ........**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ** ..............

# លិខិតធានា

# ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម**...............

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស........................................................ បានទទួលលិខិតស្ដីពីការចុះកិច្ចសន្យាការផ្គត់ផ្គង់សេវាកម្មផ្ញើ កង់ ម៉ូតូ និងរថយន្ត លេខ ............. ចុះថ្ងៃទី........ ខែ ............ ឆ្នាំ.............. ដែលមានតម្លៃកិច្ចសន្យាចំនួន........................... (សរសេរជាអក្សរ..............................................) ។

ដោយមានចែងនៅក្នុងលិខិតស្ដីពីការចុះកិច្ចសន្យាថា "អ្នកផ្គត់ផ្គង់" ត្រូវផ្ដល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ............. ដែលមានតម្លៃទឹកប្រាក់ស្មើនឹងដប់ (១០%)ភាគរយ នៃតម្លៃកិច្ចសន្យាសរុប ដើម្បីធានាការអនុវត្តកាតព្វកិច្ចស្របតាមលក្ខខណ្ឌកិច្ចសន្យា ។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ............. សូមធានា និងទទួលខុសត្រូវ នូវប្រាក់កក់ចំនួន.................. (សរសេរជាអក្សរ ............................................. )។

ប្រាក់កក់ខាងលើនេះ នឹងត្រូវបង្វែរចូលថវិការដ្ឋ នៅពេលបានទទួលលិខិតស្នើសុំពី "អ្នកទិញ" ដែលបញ្ជាក់ថា "អ្នកផ្គត់ផ្គង់" មិនគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយក្រុមហ៊ុន/សហគ្រាស .............................. គ្មានសិទ្ធិប្រកែក ឬតវ៉ាឡើយ ។

លិខិតធានានេះមានសុពលភាពរហូតដល់ ក្រោយថ្ងៃប្រគល់ ទទួលទំនិញគ្រប់ចំនួន ឬក្រោយរយៈពេលធានាគុណភាពទំនិញ ។

............... ថ្ងៃទី ............ ខែ........... ឆ្នាំ...........

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ**............

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាស

# ស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ

ខ្ញុំបាទ/នាងខ្ញុំជាប្រធានក្រុមហ៊ុន/សហគ្រាស.......................................................................... សូមធ្វើការអះអាងក្នុងការរៀបចំសំណើដេញថ្លៃលើការផ្គត់ផ្គង់សេវាកម្មផ្ញើ កង់ ម៉ូតូ និងរថយន្ត ដូចខាងក្រោម ៖

១- មិនមាននិយោជិត សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូ ឬញាតិសន្តានរបស់ខ្ញុំបាទ/នាងខ្ញុំ មានទំនាក់ទំនងណាមួយដែលអាចចាត់ទុកថាជាទំនាស់ផលប្រយោជន៍ ពាក់ព័ន្ធនឹងការដេញថ្លៃនេះទេ។

២- ប្រសិនបើខ្ញុំបាទ/នាងខ្ញុំដឹងពីលទ្ធភាពដែលអាចកើតមាននូវទំនាស់ផលប្រយោជន៍នេះ ខ្ញុំបាទ/នាងខ្ញុំ នឹងរាយការណ៍ជាបន្ទាន់ជូនស្ថាប័នអនុវត្តលទ្ធកម្ម ។

៣- មិនមានការប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត ឬបង្ខិតបង្ខំ ទាក់ទិននឹងការដាក់សំណើដេញថ្លៃរបស់ក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំ ។

៤- ខ្ញុំបាទ/នាងខ្ញុំយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការអនុញ្ញាតឱ្យស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល ឬដៃគូអភិវឌ្ឍន៍ ធ្វើអធិការកិច្ចលើរាល់លិខិតស្នាមទាំងអស់ទាក់ទងនឹងការដាក់សំណើដេញថ្លៃរបស់ក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំនិងកិច្ចសន្យាណាមួយ ដែលជាលទ្ធផលនៃការដាក់ដេញថ្លៃនេះ ដោយមិនគិតថាក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំបាន ឬមិនបានទទួលការសម្រេចប្រគល់កិច្ចសន្យានោះទេ ។

៥- គ្មានការទូទាត់ណាមួយ ទាក់ទងនឹងដំណើរការលទ្ធកម្មនេះ ត្រូវបានធ្វើឡើងដោយខ្ញុំបាទ/នាងខ្ញុំ សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូរបស់ខ្ញុំបាទ/នាងខ្ញុំ ឬញាតិសន្តានរបស់ពួកគេ ទៅឱ្យភ្នាក់ងារ ទីប្រឹក្សា និយោជិត ឬញាតិសន្តានរបស់ពួកគេ ដែលចូលរួមក្នុងដំណើរការលទ្ធកម្មនេះ ជំនួសមុខឱ្យស្ថាប័នអនុវត្តលទ្ធកម្ម អតិថិជន ឬនិយោជកនោះទេ ។

ធ្វើនៅ ................. ថ្ងៃទី ............. ខែ ............ ឆ្នាំ .............

ហត្ថលេខា

ឈ្មោះ........................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន...............................................**
**អាស័យដ្ឋាន.....................................**
**លេខ..................................................**

## ពាក្យសុំដេញថ្លៃជុំទី ១

ខ្ញុំបាទ_នាងខ្ញុំ........................ មុខងារ.................................. ក្រុមហ៊ុន.................................... អាស័យដ្ឋាន.................................................................................................................................... ទូរស័ព្ទ.........................................

**សូមគោរពជូន**
**ឯកឧត្តមប្រធានគណៈកម្មាធិការលទ្ធកម្ម នៃ ស.ភ.ន.ව.ស**

យោងសេចក្តីជូនដំណឹងលេខ..................សភនវស-១៥ ចុះថ្ងៃទី...........ខែ...............ឆ្នាំ២០១៥ ស្តីពីការដាក់អោយដេញថ្លៃធ្វើអាជីវកម្ម ផ្ញើកង់ ម៉ូតូ និងរថយន្ត នៅក្នុងបរិវេណនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ខ្ញុំបាទ_នាងខ្ញុំ សូមដាក់នូវតម្លៃប្រចាំខែនៃការធ្វើអាជីវកម្ម ផ្ញើកង់ ម៉ូតូ និងរថយន្ត ជូនគណៈកម្មាធិការលទ្ធកម្ម នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាទឹកប្រាក់ចំនួន..................................(ជាអក្សរ).................................................................................................. តាមវិធីសាស្ត្រដេញថ្លៃឡើងនៃតម្លៃគោលខ្ពស់បំផុត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.............. ខែ.................... ឆ្នាំ២០១៥
ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន..............................................**
**អាស័យដ្ឋាន......................................**
**លេខ..................................................**

## ពាក្យសុំដេញថ្លៃជុំទី ២

ខ្ញុំបាទ_នាងខ្ញុំ............................មុខងារ............................ក្រុមហ៊ុន...........................................
អាស័យដ្ឋាន...................................................................................................................................
ទូរស័ព្ទ........................................

**សូមគោរពជូន**
**ឯកឧត្តមប្រធានគណ:កម្មាធិការលទ្ធកម្ម នៃ ស.ភ.ន.វ.ស**

យោងសេចក្ដីជូនដំណឹងលេខ..................សភនវស-១៥ ចុះថ្ងៃទី...........ខែ...............ឆ្នាំ២០១៥ ស្ដីពីការដាក់អោយដេញថ្លៃធ្វើអាជីវកម្ម ផ្ញើកង់ ម៉ូតូ និងរថយន្ត នៅក្នុងបរិវេណនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

ខ្ញុំបាទ_នាងខ្ញុំ សូមដាក់នូវតម្លៃប្រចាំខែនៃការធ្វើអាជីវកម្ម ផ្ញើកង់ ម៉ូតូ និងរថយន្ត ជូនគណ:កម្មាធិការលទ្ធកម្ម នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាទឹកប្រាក់ ចំនួន.................................(ជាអក្សរ)....................................................................................... តាមវិធីសាស្រ្តដេញថ្លៃឡើងនៃតម្លៃខ្ពស់បំផុត នៅជុំទី ១ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.............. ខែ.................... ឆ្នាំ២០១៥
ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន................................................**
**អាស័យដ្ឋាន......................................**
**លេខ..................................................**

## ពាក្យសុំដេញថ្លៃជុំទី ៣

ខ្ញុំបាទ_នាងខ្ញុំ..............................មុខងារ..............................ក្រុមហ៊ុន....................................
អាស័យដ្ឋាន.................................................................................................................................
ទូរស័ព្ទ........................................

**សូមគោរពជូន**
**ឯកឧត្តមប្រធានគណៈកម្មាធិការលទ្ធកម្ម នៃ ស.ភ.ន.វ.ស**

យោងសេចក្តីជូនដំណឹងលេខ..................សភនវស-១៥ ចុះថ្ងៃទី...........ខែ................ឆ្នាំ២០១៥ ស្តីពីការដាក់អោយដេញថ្លៃធ្វើអាជីវកម្ម ផ្ញើកង់ ម៉ូតូ និងរថយន្ត នៅក្នុងបរិវេណនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

ខ្ញុំបាទ_នាងខ្ញុំ សូមដាក់នូវតម្លៃប្រចាំខែនៃការធ្វើអាជីវកម្ម ផ្ញើកង់ ម៉ូតូ និងរថយន្ត ជូនគណៈកម្មាធិការលទ្ធកម្ម នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាទឹកប្រាក់ចំនួន..............................(ជាអក្សរ)...............................................................................................
តាមវិធីសាស្រ្តដេញថ្លៃឡើងនៃតម្លៃខ្ពស់បំផុត នៅជុំទី ២ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.............. ខែ................... ឆ្នាំ២០១៥
ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ

# ផ្នែកទី១
# សេចក្ដីណែនាំចំពោះអ្នកដេញថ្លៃ

**ប្រការ១ ៖ វិសាលភាពនៃការដេញថ្លៃ**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (**ស.ភ.ន.វ.ស**) នឹងដាក់ឲ្យដេញថ្លៃប្រកួតប្រជែងជាសាធារណៈលើការផ្ដល់សេវាកម្មផ្ញើ កង់ ម៉ូតូ និងរថយន្ត សម្រាប់និស្សិតនៃសាកលវិទ្យាល័យ ក្នុងមួយអាណត្តិមានរយៈពេល ០២ (ពីរ) ឆ្នាំ ។

**ប្រការ២ ៖ ចំណូល**

ចំណូលដែលទទួលបានពីការដេញថ្លៃ ត្រូវដាក់ចូលជាថវិការបស់ **ស.ភ.ន.វ.ស** ។

**ប្រការ៣ ៖ អ្នកដែលមានសិទ្ធិដេញថ្លៃ**

**៣.១.**ការដេញថ្លៃនេះ បើកចំហរចំពោះក្រុមហ៊ុនក្នុងស្រុក គិតទាំងសហគ្រាសឯកត្តបុគ្គល និងក្រុមហ៊ុនបរទេសទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**៣.២.**អ្នកដែលមានការពាក់ពន្ធ័ ឬធ្លាប់មានការពាក់ពន្ធ័ពីមុនមក ជាមួយទីប្រឹក្សា ឬ អង្គភាពដទៃទៀតសម្រាប់គម្រោងរបស់ ស.ភ.ន.វ.ស គ្មានសិទ្ធិក្នុងការចូលរួមដេញថ្លៃនេះទេ ។

**៣.៣.**អ្នកដេញថ្លៃមិនត្រូវមានទំនាស់ផលប្រយោជន៍នោះទេ ។ អ្នកដេញថ្លៃទាំងអស់ ដែលបានរកឃើញថាមានទំនាស់ផលប្រយោជន៍នឹងត្រូវបានដកសិទ្ធិ ។ អ្នកដេញថ្លៃអាចត្រូវបានចាត់ទុកថាមានទំនាស់ផលប្រយោជន៍ ប្រសិនបើអ្នកដេញថ្លៃទាំងនោះ មានលក្ខណៈដូចខាងក្រោម៖

**ក.**មានម្ចាស់ភាគហ៊ុនគ្រប់គ្រងដូចគ្នា ឬមានសម្ព័ន្ធភាពជាមួយគ្នា ។

**ខ.**ធ្លាប់បានចូលរួមពីមុនមក ទោះដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី ជាមួយ ស.ភ.ន.វ.ស ឬ អង្គភាពដទៃណាមួយ ដែលជួយរៀបចំកំណត់អំពីសេចក្ដីត្រូវការ ។

**គ.**បានចូលរួមចំណែកក្នុងការរៀបចំយថាប្រភេទ និងឯកសារដទៃទៀតសម្រាប់គម្រោង ឬកិច្ចលទ្ធកម្មនេះ ។

**ឃ.**ទទួល ឬធ្លាប់បានទទួលការជួយឧបត្ថម្ភដោយផ្ទាល់ ឬដោយប្រយោលពីអ្នកដេញថ្លៃណា មួយ ។

**ង.**មានអ្នកតំណាងដែលបានសិទ្ធិដូចគ្នា សម្រាប់គោលបំណងនៃការដាក់ដេញថ្លៃតែមួយ ។

**ច.**មានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកដោយផ្ទាល់ ឬតាមរយៈតតិយជន ដែលធ្វើឲ្យពួកគេមានលទ្ធភាពទទួលបានពត៌មាន ឬមានឥទ្ធិពលលើការដេញថ្លៃ របស់អ្នកដេញថ្លៃដទៃទៀត ។

**ឆ.**បុគ្គលិកជាន់ខ្ពស់ ឬម្ចាស់ភាគហ៊ុនគ្រប់គ្រង មានការពាក់ពន្ធ័ទៅនឹងមន្ត្រីណាមួយរបស់ ស.ភ.ន.វ.ស ដែលបានចូលរួមក្នុងការធ្វើលទ្ធកម្មនេះ ។

៣.៤.អ្នកដេញថ្លៃ ឬអ្នកផ្គត់ផ្គង់បន្ត ត្រូវទទួលខុសត្រូវចំពោះអំពើពុករលួយ អំពើក្លែងបន្លំ អំពើឃុបឃិត និងអំពើបង្ខិតបង្ខំ ។

៣.៥.សហគ្រាសរបស់រដ្ឋ អាចមានសិទ្ធិក្នុងការចូលរួមដេញថ្លៃបាន ប្រសិនបើសហគ្រាសទាំងនោះស្របច្បាប់ និងមានស្វ័យភាពហិរញ្ញវត្ថុ ហើយធ្វើអាជីវកម្មស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្ម និងមិនមែនជាអង្គភាព ឬភ្នាក់ងាររបស់ ស.ភ.ន.វ.ស ។

៣.៦.អ្នកដេញថ្លៃទាំងអស់ តម្រូវឲ្យបំពេញ និងភ្ជាប់មកជាមួយសំណើដេញថ្លៃរបស់ខ្លួននូវទម្រង់ឯកសារសមស្របដូចមានរៀបរាប់នៅក្នុងប្រការ ៥ វាក្យខណ្ឌទី៣ ចំនុច គ.ឃ និង ង ប្រការ៧ និងប្រការ៦២ វាក្យខណ្ឌទី៨ នៃសេចក្តីណែនាំចំពោះអ្នកដេញថ្លៃ ។

**ប្រការ៤ ៖ សំណើដេញថ្លៃមួយសម្រាប់អ្នកដេញថ្លៃមួយ**

អ្នកដេញថ្លៃនីមួយៗ អាចដាក់សំណើដេញថ្លៃបានតែមួយប៉ុណ្ណោះ ទោះបីជាបុគ្គលខ្លួនឯងក្តី ឬជាដៃគូរក្នុងក្រុមហ៊ុនរួមទុនក្តី។ អ្នកដេញថ្លៃដែលដាក់សំណើដេញថ្លៃលើសពីមួយ នឹងបណ្តាលឲ្យសំណើដេញថ្លៃរបស់ខ្លួនទាំងអស់ត្រូវបានបដិសេធ ។

**ប្រការ៥ ៖ លក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃ**

៥.១.នៅពេលដាក់សំណើដេញថ្លៃ អ្នកដេញថ្លៃត្រូវភ្ជាប់ឯកសារភស្តុតាង បង្ហាញពីលក្ខណៈសម្បត្តិរបស់ខ្លួនជូន ស.ភ.ន.វ.ស ដូចខាងក្រោម៖

ក.អ្នកដេញថ្លៃមានសមត្ថភាពផ្នែកហិរញ្ញវត្ថុ បច្ចេកទេសត្រឹមត្រូវ ក្នុងការអនុវត្តតាមកិច្ចសន្យា។

ខ.ក្នុងករណីអ្នកដេញថ្លៃមិនមានធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា អ្នកដេញថ្លៃត្រូវមានតំណាងរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ដែលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តកាតព្វកិច្ច របស់ខ្លួនយ៉ាងពេញលេញស្របតាមច្បាប់ និងតាមលក្ខខណ្ឌនៃកិច្ចសន្យា ។

គ.អ្នកដេញថ្លៃបំពេញបាននូវលក្ខណៈវិនិច្ឆ័យនៃលក្ខណៈសម្បត្តិបន្ថែមដទៃទៀត ។

៥.២.សំណើដេញថ្លៃដែលដាក់ដោយក្រុមហ៊ុនរួមទុនរវាងក្រុមហ៊ុនពីរ ឬច្រើន ជាដៃគូរត្រូវអនុវត្តតាមការតម្រូវដូចខាងក្រោម៖

ក.សំណើដេញថ្លៃត្រូវមានបញ្ចូលនូវពត៌មានទាំងអស់ អំពីដៃគូរនីមួយៗនៃក្រុមហ៊ុនរួមទុន ។

ខ.រាល់ដៃគូរទាំងអស់ត្រូវបំពេញតាមការតម្រូវពីភាពមានសិទ្ធិចូលរួមដេញថ្លៃ ។

គ.សំណើដេញថ្លៃត្រូវចុះហត្ថលេខា ដើម្បីឲ្យមានកាតព្វកិច្ចចងភ្ជាប់ស្របច្បាប់ចំពោះដៃគូរទាំងអស់ ។

ឃ.ដៃគូរទាំងអស់ត្រូវទទួលខុសត្រូវរួមគ្នា ក្នុងការអនុវត្តកិច្ចសន្យា ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចសន្យា ។

ង.ដៃគូរមួយក្នុងចំណោមដៃគូរទាំងអស់ នឹង ត្រូវជ្រើសតាំងជាអ្នកទទួលបន្ទុក ដែលបានផ្តល់

សិទ្ធិឲ្យចុះហត្ថលេខា លើសំណើដេញថ្លៃ ឲ្យបង្កើតនូវការទទួលខុសត្រូវ និងឲ្យទទួលសេចក្តីណែនាំជំនួសរាល់ដៃគូរទាំងអស់នៃក្រុមហ៊ុនរួមទុន ។

ច.ការអនុវត្តកិច្ចសន្យាទាំងមូលរួមបញ្ចូលទាំងការទូទាត់ ត្រូវធ្វើឡើងទាំងស្រុងជាដៃគូរទទួលបន្ទុក ។

ឆ.ក្រុមហ៊ុនរួមទុន ត្រូវផ្តល់នូវឯកសារចម្លង នៃកិច្ចព្រមព្រៀងរបស់ក្រុមហ៊ុនរួមទុនរបស់ខ្លួន។ ប្រសិនបើពុំមានកិច្ចព្រមព្រៀងនេះទេ ត្រូវផ្តល់នូវអនុស្សារណៈនៃកិច្ចព្រមព្រៀងចុះហត្ថលេខា ដោយដៃគូសក្តានុពលទាំងអស់។ លិខិតបញ្ជាក់អំពីគោលបំណង ត្រូវទទួលស្គាល់នូវការទទួលខុសត្រូវរួមគ្នារបស់ភាគីនានាទាក់ទងនឹងកិច្ចសន្យាដែលត្រូវផ្តល់ឲ្យក្រុមហ៊ុនរួមទុននេះ ។

៥.៣.ដើម្បីមានសិទ្ធិទទួលបាននូវការសំរេចប្រគល់កិច្ចសន្យា អ្នកដេញថ្លៃត្រូវបំពេញនូវលក្ខខណ្ឌអប្បបរមា (ក្រោយពេលលក្ខណៈសម្បត្តិគ្រប់គ្រាន់) ដូចខាងក្រោម៖

ក.មានឋានៈស្របច្បាប់នៅក្នុងប្រទេសមានសិទ្ធិចូលរួមដេញថ្លៃ ។

ខ.ធ្វើការស្នើផ្គត់ផ្គង់ទំនិញ និងសេវាកម្មពីប្រទេសមានសិទ្ធិចូលរួមដេញថ្លៃ ។

**ប្រការ៦ ៖ ការចំណាយសម្រាប់ការដេញថ្លៃ**

អ្នកដេញថ្លៃ ត្រូវទទួលបន្ទុករាល់ចំណាយទាំងអស់ពាក់ព័ន្ធនឹងការរៀបចំ និងការដាក់សំណើដេញ ថ្លៃ ហើយ ស.ភ.ន.វ.ស មិនទទួលខុសត្រូវលើការចំណាយទាំងនេះឡើយ ។

**ប្រការ៧ ៖ សមាសភាពនៃឯកសារដេញថ្លៃ**

៧.១.ឯកសារដេញថ្លៃត្រូវរួមបញ្ចូលឯកសារដូចខាងក្រោម៖

១.សេចក្តីជូនដំណឹង

២.សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ

៣.លក្ខខណ្ឌទូទៅនៃកិច្ចសន្យា

៤.ពាក្យសុំដេញថ្លៃ (បិទតែមប្រ៊ីយ ៥០០០រៀល)

៥.បណ្ណ័ប៉ាតង់ប្រចាំឆ្នាំ២០១៥

៦.វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

៧.លិខិតធានាលើប្រាក់កក់ធានាការដេញថ្លៃចំនួន ២%

៨.ឧបសម្ព័ន្ធបំពេញដោយដៃ (ទឹកប៊ិចខៀវ លុបមិនជ្រះ)

៩.ឯកសារភ្ជាប់ដូចមានចែងក្នុងប្រការ ៥

(៤–៩) **ឧបសម្ព័ន្ធត្រូវបំពេញដោយអ្នកដេញថ្លៃ**

៧.២.អ្នកដេញថ្លៃត្រូវយកចិត្តទុកដាក់ពិនិត្យមើលរាល់សេចក្តីណែនាំ ទម្រង់លក្ខខណ្ឌនានា និងលក្ខណៈបច្ចេកទេសក្នុងឯកសារដេញថ្លៃ។ គណៈកម្មាធិការលទ្ធកម្មមានសិទ្ធិបដិសេធចោល នូវឯកសារដេញថ្លៃណាមួយ ក្នុងករណីដែលអ្នកដេញថ្លៃខកខានមិនបានផ្តល់ពត៌មានចាំបាច់ ដែលតម្រូវក្នុងឯកសារដេញថ្លៃ ។

**ប្រការ៨ ៖ សេចក្ដីបញ្ជាក់លើឯកសារដេញថ្លៃ**

៨.១.អ្នកដេញថ្លៃដែលស្នើសុំឲ្យធ្វើសេចក្ដីបញ្ជាក់ចំណុចខ្លះៗនៃឯកសារដេញថ្លៃ អាចជូនដំណឹង ទៅ ស.ភ.ន.វ.ស តាមរយៈអង្គភាពលទ្ធកម្មជាលាយល័ក្ខណ៍អក្សរ ឬទូរសារទៅអាស័យដ្ឋានដែលបានកំណត់នៅក្នុងសេចក្ដីជូនដំណឹងស្ដីពីការដេញថ្លៃ ។ សំណើនេះត្រូវបានទទួលមិនតិចជាង ១៤ថ្ងៃ មុនកាលបរិច្ឆេទផុតកំណត់ទទួលសំណើដេញថ្លៃ ។

៨.២.ស.ភ.ន.វ.ស ត្រូវបញ្ជូនឯកសារចម្លង នៃការឆ្លើយតបរបស់ខ្លួន ទៅរាល់អ្នកដេញថ្លៃទាំងអស់ដែលបានទទួលឯកសារមិនឲ្យលើស ៣ ថ្ងៃមុនកាលបរិច្ឆេទផុតកំណត់ទទួលសំណើដេញថ្លៃ ។ ការឆ្លើយតបនេះ មានបញ្ចូលព័ត៌មាននានាអំពីការចោទសួរ ប៉ុន្តែមិនត្រូវបញ្ជាក់ពីប្រភពនៃការចោទសួរទេ ។ ក្នុងករណីចាំបាច់តាមរយៈលទ្ធផលនៃការបញ្ជាក់នេះ ស.ភ.ន.វ.ស អាចធ្វើការកែប្រែឯកសារដេញថ្លៃ ។

**ប្រការ៩ ៖ ការកែប្រែឯកសារដេញថ្លៃ**

៩.១.ក្នុងករណីចាំបាច់ អ្នកដេញថ្លៃ អាចកែប្រែឯកសារដេញថ្លៃ មុនកាលបរិច្ឆេទផុតកំណត់ទទួលសំណើដេញថ្លៃ ដោយធ្វើការចេញសេចក្ដីបន្ថែម ។ រាល់ការកែប្រែលើឯកសារដេញថ្លៃត្រូវមានការយល់ព្រមពី ស.ភ.ន.វ.ស ជាមុន ។

៩.២.សេចក្ដីបន្ថែមណាមួយដែលបានធ្វើឡើងត្រូវជាផ្នែកមួយនៃឯកសារដេញថ្លៃ ហើយត្រូវផ្ញើជូនគ្រប់អ្នកដែលបានទទួលឯកសារដេញថ្លៃទាំងអស់ ។

៩.៣.ស.ភ.ន.វ.ស អាចពន្យាកាលបរិច្ឆេទផុតកំណត់ទទួលសំណើដេញថ្លៃ ដើម្បីផ្ដល់ឲ្យអ្នកដេញថ្លៃនូវពេលវេលាសមរម្យក្នុងការពិចារណាសេចក្ដីបន្ថែមសម្រាប់ការរៀបចំសំណើដេញថ្លៃរបស់ខ្លួនឡើងវិញ។

**ប្រការ១០ ៖ ភាសានៃសំណើដេញថ្លៃ**

ឯកសារទាំងអស់ទាក់ទងនឹងសំណើដេញថ្លៃត្រូវធ្វើជាភាសាខ្មែរ ។ សំណើដេញថ្លៃណាមួយ ដែលរៀបចំជាភាសាបរទេសត្រូវបកប្រែជាភាសាខ្មែរ ។ ក្នុងករណីដែលមានភាពមិនស្របគ្នានៃភាសាខ្មែរ និងភាសាបរទេសនោះ ឯកសារជាភាសាខ្មែរជាឯកសារផ្លូវការ ។

**ប្រការ១១ ៖ ឯកសាររួមបញ្ចូលក្នុងឯកសារដេញថ្លៃ**

សំណើដេញថ្លៃដែលរៀបចំឡើងដោយអ្នកដេញថ្លៃត្រូវមានឯកសារដូចខាងក្រោម៖

ក.ពាក្យសុំដេញថ្លៃ និងតារាងតម្លៃ ត្រូវបំពេញឲ្យបានត្រឹមត្រូវស្របតាមការណែនាំ ដូចមានបញ្ជាក់ក្នុងឯកសារដេញថ្លៃ ។

ខ.សេចក្ដីបញ្ជាក់ជាលាយល័ក្ខណ៍អក្សរផ្ដល់សិទ្ធិហត្ថលេខីលើសំណើដេញថ្លៃ ។

គ.ឯកសារភស្តុតាងបញ្ជាក់ពីអ្នកដេញថ្លៃ (តំណាងស្របច្បាប់) មានសិទ្ធិចូលរួមដេញថ្លៃ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យា ប្រសិនបើសំណើដេញថ្លៃរបស់ខ្លួនត្រូវបាន ទទួលយក ។

ឃ.ឯកសារភស្តុតាងធានាថា សេវាកម្មដែលនឹងត្រូវបានផ្តល់ដោយអ្នកដេញថ្លៃ គឺសេវាកម្មដែលបានអនុញ្ញាត ហើយអនុលោមតាមឧបសម្ព័ន្ធភ្ជាប់ឯកសារដេញថ្លៃនេះ។

ង.ប្រាក់កក់ធានាការដេញថ្លៃ ឬលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ។

**ប្រការ១២ ៖ ភាពមានសិទ្ធិចូលរួមរបស់អ្នកដេញថ្លៃ**

១២.១.អ្នកដេញថ្លៃ ត្រូវផ្តល់ឯកសារបញ្ជាក់ពីភាពមានសិទ្ធិចូលរួមដេញថ្លៃ និងលក្ខណៈសម្បត្តិរបស់ខ្លួនក្នុងការអនុវត្តកិច្ចសន្យា ប្រសិនបើសំណើដេញថ្លៃត្រូវបានទទួលយក ។

១២.២.ដើម្បីបង្កើតនូវលក្ខណៈសម្បត្តិរបស់ខ្លួនក្នុងការអនុវត្តកិច្ចសន្យា អ្នកដេញថ្លៃត្រូវភ្ជាប់នូវ ៖

ក.ឯកសារចម្លងនៃឯកសារច្បាប់ដើម ដែលកំណត់អំពីឋានៈស្របច្បាប់ ទីកន្លែងនៃការចុះបញ្ជី និងទីស្នាក់ការធ្វើអាជីវកម្ម ។

ខ.លិខិតប្រទានសិទ្ធិជាលាយលក្ខណ៍អក្សរដល់ហត្ថលេខីលើសំណើដេញថ្លៃ ។

គ.ចំណូលប្រចាំឆ្នាំសរុបសម្រាប់ឆ្នាំនីមួយៗ នៃរយៈពេល២ឆ្នាំមុន ដោយមានភស្តុតាងជារបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវធ្វើសវនកម្មពីខាងក្រៅ ឬរបាយការណ៍បង់ពន្ធប្រចាំឆ្នាំ ។

ឃ.ភស្តុតាងនៃកិច្ចសន្យាយ៉ាងតិចមួយសម្រាប់សេវាកម្មប្រហាក់ប្រហែលគ្នា សមមូលទៅនឹង៥០% ឬច្រើន ជាងនេះនៃតម្លៃនៃការដាក់ដេញថ្លៃ ដែលបានបញ្ចប់នៅក្នុងរយៈពេល ៣ឆ្នាំមុន ។

ង.ភស្តុតាងនៃភាពគ្រប់គ្រងនៃទុនបង្វិលសម្រាប់កិច្ចសន្យានេះ (លទ្ធផលទទួលបានឥណទាន លក្ខខណ្ឌឥណទាន ដែលបានព្រមព្រៀងជាមួយនឹងអ្នកផ្តល់ ឬទ្រព្យសកម្ម និងសារពើភណ្ឌ) ។

ច.ការអនុញ្ញាតស្វែងរកសេចក្តីបញ្ជាក់ពីធនាគាររបស់អ្នកដេញថ្លៃ ។

**ប្រការ១៣ ៖ ឯកសារបញ្ជាក់នូវភាពសមស្របសេវាកម្មពាក់ព័ន្ធ**

ឯកសារបញ្ជាក់នូវភាពសមស្របនៃសេវាកម្មនៃឯកសារដេញថ្លៃ អាចមានទម្រង់ជាអក្សរ គំនូរ និងទិន្នន័យ ហើយត្រូវមានការពិពណ៌នាលំអិតអំពីលក្ខណៈបច្ចេកទេស នៃសេវាកម្មដែលត្រូវផ្គត់ផ្គង់ ។

**ប្រការ១៤ ៖ សំណើដេញថ្លៃផ្សេងទៀត**

អ្នកដេញថ្លៃ ត្រូវដាក់សំណើដេញថ្លៃ ដោយអនុលោមតាមសេចក្តីណែនាំចំពោះអ្នកដេញថ្លៃ។ សំណើដេញថ្លៃផ្សេងទៀតដែលមិនអនុលោមតាមសេចក្តីណែនាំ មិនត្រូវយកមកពិចារណាឡើយ ។

**ប្រការ១៥ ៖ តម្លៃដាក់ដេញថ្លៃ**

១៥.១.អ្នកដេញថ្លៃ ត្រូវបំពេញតម្លៃក្នុងពាក្យសុំចូលរួមដេញថ្លៃ ដោយសរសេរជាលេខ និងអក្សរ។

១៥.២.អ្នកដេញថ្លៃដាក់តម្លៃថេរក្នុងពេលអនុវត្តកិច្ចសន្យារបស់ខ្លួន និង មិនមែនជាកម្មវត្ថុសម្រាប់ធ្វើការផ្លាស់ប្តូរនោះទេ ទោះក្នុងកាលៈទេសៈណាក៏ដោយ ។ សំណើដេញថ្លៃណាមួយដែលដាក់តម្លៃប្រែប្រួល ត្រូវចាត់ទុកថាមិនឆ្លើយតបហើយចាត់ទុកជាមោឃៈ ។

១៥.៣.តម្លៃដាក់ដេញថ្លៃត្រូវជាប្រាក់រៀល។ ប្រសិនបើដាក់ជារូបិយបណ្ណបរទេស ត្រូវប្តូរជាប្រាក់

រៀល តាមអត្រាប្តូរប្រាក់ (តម្លៃលក់) របស់ធនាគារជាតិនៃកម្ពុជា នាថ្ងៃបើកសំណើដេញថ្លៃ ។

១៥.៤.សំណើដេញថ្លៃមិនត្រូវមានការផ្លាស់ប្តូរ ការបន្ថែមនោះទេ លើកលែងតែការផ្លាស់ប្តូរ ឬការបន្ថែមនោះប្រតិបត្តិតាមការណែនាំដែលធ្វើឡើងដោយ ស.ភ.ន.វ.ស ។

**ប្រការ១៦ ៖ ការចុះហត្ថលេខាលើសំណើដេញថ្លៃ**

ឯកសារច្បាប់ដើម និងឯកសារច្បាប់ថតចម្លងទាំងអស់នៃសំណើដេញថ្លៃ ត្រូវបំពេញដោយដៃ ដោយប្រើប្រាស់ ទឹកប៊ិចពណ៌ខៀវដែលមិនអាចលុបជ្រះ និងត្រូវចុះហត្ថលេខាដោយអ្នកដេញថ្លៃ ឬអ្នកដែលបានទទួលសិទ្ធិពេញលេញដើម្បីចុះហត្ថលេខាជំនួសមុខអ្នកដេញថ្លៃ ។ រាល់ទំព័រទាំងអស់នៃសំណើដេញថ្លៃដែលមានការបញ្ចូលបន្ថែម ឬ ការកែប្រែ ត្រូវចុះហត្ថលេខាសង្ខេប (Griffe) ដោយអ្នកដែលចុះហត្ថលេខា លើសំណើដេញថ្លៃ ។

**ប្រការ១៧ ៖ សុពលភាពនៃសំណើដេញថ្លៃ**

១៧.១.សំណើដេញថ្លៃត្រូវមានសុពលភាពរយៈពេលយ៉ាងតិច ៣០ថ្ងៃ បន្ទាប់ពីផុតកាលបរិច្ឆេទនៃការទទួលសំណើដេញថ្លៃ ។ សំណើដេញថ្លៃដែលមានសុពលភាពរយៈពេលខ្លីជាងនេះ នឹងត្រូវបដិសេធដោយស.ភ.ន.វ.ស ។

១៧.២.ក្នុងកាលៈទេសៈពិសេស នៅមុនពេលផុតកំណត់រយៈពេលសុពលភាពនៃសំណើដេញថ្លៃ ស.ភ.ន.វ.ស អាចស្នើឲ្យអ្នកដេញថ្លៃ ពន្យាររយៈពេលសុពលភាពនៃសំណើដេញថ្លៃរបស់ពួកគេបាន។ ការស្នើ និងការឆ្លើយតបត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ រីឯលិខិតធានាប្រាក់កក់ធានាការដេញថ្លៃក៏ត្រូវបានពន្យារសុពលភាពសម្រាប់រយៈពេលដូចគ្នាដែរ។ អ្នកដេញថ្លៃអាចមិនយល់ព្រមចំពោះការស្នើសុំពន្យារសុពលភាព ដោយមិនមានបាត់បង់ប្រាក់កក់ធានានោះទេ។ អ្នកដេញថ្លៃដែលយល់ព្រមតាមការពន្យារ មិនត្រូវបានតម្រូវ ឬអនុញ្ញាតឲ្យមានការកែប្រែសំណើដេញថ្លៃរបស់ខ្លួននោះទេ ។

**ប្រការ១៨ ៖ ប្រាក់កក់ធានាដេញថ្លៃ**

១៨.១.អ្នកដេញថ្លៃត្រូវផ្តល់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ ដែលមានចំនួនទឹកប្រាក់យ៉ាងតិចស្មើ ២% នៃតម្លៃដាក់ដេញថ្លៃគោល ដែលក្រុមហ៊ុនបានកក់នៅធនាគារជាតិនៃកម្ពុជា ឬរតនាគារជាតិនៃរាជធានី-ខេត្តណាមួយ ឬធនាគារដែលបានចុះអនុសារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.២.ប្រាក់កក់នេះបញ្ជាក់ពីកាតព្វកិច្ចរបស់អ្នកដេញថ្លៃ ក្នុងការរក្សាសំណើដេញថ្លៃរបស់ខ្លួនឲ្យមានសុពលភាពក្នុងរយៈពេលដេញថ្លៃ ។

១៨.៣.លិខិតធានាប្រាក់កក់ធានាដេញថ្លៃនេះ ត្រូវមានសុពលភាពរហូតដល់ ៣០ ថ្ងៃបន្ទាប់ពីផុតសុពលភាពសំណើដេញថ្លៃ ។

១៨.៤.សំណើដេញថ្លៃដែលមិនភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការដេញថ្លៃទេ នឹងត្រូវបដិសេធដោយចាត់ទុកថាមិនឆ្លើយតបតាមសេចក្តីណែនាំ ។

១៨.៥.ចំពោះប្រាក់កក់អ្នកដេញថ្លៃចាញ់ នឹងបង្វែរជូនវិញមិនឲ្យហួសពី ០៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីអ្នកដេញថ្លៃឈ្នះទទួលចុះកិច្ចសន្យា និងបានបង់ប្រាក់ធានាការអនុវត្ត ។

១៨.៦.ចំពោះអ្នកដេញថ្លៃឈ្នះ ប្រាក់កក់នេះត្រូវបង្វែរជូនវិញ បន្ទាប់ពីអ្នកដេញថ្លៃនេះបានចុះហត្ថលេខាលើកិច្ចសន្យា និងបានបង់ប្រាក់កក់ធានាការអនុវត្ត ។

១៨.៧.ប្រាក់កក់ធានាការដេញថ្លៃនឹងត្រូវរឹបអូសបង្វែរចូលថវិកា ស.ភ.ន.វ.ស ប្រសិនបើ ៖

ក.អ្នកដេញថ្លៃដកសំណើរបស់ខ្លួនវិញក្នុងរយៈពេលសុពលភាព នៃសំណើដេញថ្លៃដែលមិនទាន់ប្រកាសលទ្ធផលជ័យលាភី នៃអ្នកដេញថ្លៃឈ្នះ ។

ខ.អ្នកដេញថ្លៃឈ្នះ មិនទទួលយកការកែតម្រូវ វេខាគណិតនៃសំណើដេញថ្លៃរបស់ខ្លួន ។

គ.អ្នកដេញថ្លៃឈ្នះ មិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ឬ មិនព្រមផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្ត ។

**ប្រការ១៩ ៖ ការបិទភ្ជិត និងការធ្វើកំណត់សំគាល់សំណើដេញថ្លៃ**

១៩.១.អ្នកដេញថ្លៃត្រូវរៀបចំសំណើដេញថ្លៃរបស់ខ្លួនចំនួន ៣ច្បាប់ ដោយត្រូវធ្វើកំណត់សំគាល់ថាច្បាប់ដើមមួយច្បាប់ និងច្បាប់ចតចម្លងពីរច្បាប់ ។

១៩.២.អ្នកដេញថ្លៃត្រូវបោះត្រាលើទំព័រច្បាប់ដើមទាំងអស់ ។ ឯកសារច្បាប់ដើមត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតមួយ ហើយច្បាប់ចតចម្លងទាំងអស់ ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតផ្សេងទៀត ដោយមានសញ្ញាសំគាល់នៅលើស្រោមសំបុត្រ ដែលអាចបញ្ជាក់ថាជាច្បាប់ដើម ឬជាច្បាប់ចតចម្លង ។

១៩.៣.លើស្រោមសំបុត្រខាងក្រៅ និងខាងក្នុងត្រូវសរសេរដូចខាងក្រោម ៖

ក.បញ្ជូនទៅ ស.ភ.ន.វ.ស តាមអាស័យដ្ឋានដូចមានបញ្ជាក់នៅក្នុងឯកសារដេញថ្លៃ ។

ខ.ឈ្មោះ អាស័យដ្ឋានរបស់អ្នកដេញថ្លៃ និងលេខសំគាល់គម្រោង។

គ.ដាក់បម្រាមមិនត្រូវបើកមុនពេលវេលា និងកាលបរិច្ឆេទកំណត់សម្រាប់ការបើកសំណើដេញថ្លៃ។

១៩.៤.ករណីស្រោមសំបុត្រណាមួយមិនបានបំពេញតាមកឋាខណ្ឌ ២០.២ និង២០.៣ នោះ ស.ភ.ន.វ.ស មិនទទួលខុសត្រូវលើការខូចខាតជាយថាហេតុឡើយ។

**ប្រការ២០ ៖ កាលបរិច្ឆេទផុតកំណត់នៃការទទួលសំណើដេញថ្លៃ**

២០.១. អ្នកដេញថ្លៃត្រូវដាក់ពាក្យសុំដេញថ្លៃ តាមកាលបរិច្ឆេទ និងពេលវេលា ដូចមានកំណត់នៅក្នុងឯកសារ ដេញថ្លៃ នៅ ស.ភ.ន.វ.ស។

២០.២.ក្នុងករណីចាំបាច់ ស.ភ.ន.វ.ស មានសិទ្ធិពន្យាកាលបរិច្ឆេទផុតកំណត់នៃការទទួលសំណើដេញថ្លៃ ដោយធ្វើការជូនដំណឹងបន្ថែម ។ នៅក្នុងករណីនេះ សិទ្ធិ និងកាតព្វកិច្ចទាំងអស់របស់ ស.ភ.ន.វ.ស និងអ្នកដេញថ្លៃដោយយោងទៅលើកាលបរិច្ឆេទពីមុនត្រូវយោងទៅកាលបរិច្ឆេទថ្មី ។

២០.៣.សំណើដេញថ្លៃណាមួយដែល ស.ភ.ន.វ.ស ទទួលក្រោយកាលបរិច្ឆេទផុតកំណត់ ត្រូវបញ្ជូន

ត្រឡប់ទៅអ្នកដេញថ្លៃវិញដោយរក្សានូវសភាពដើម។

**ប្រការ២១ ៖ ការកែប្រែ និងការដកសំណើដេញថ្លៃ**

២១.១.អ្នកដេញថ្លៃអាចធ្វើការកែប្រែ និង ដកយកវិញនូវសំណើដេញថ្លៃរបស់ខ្លួន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមុនកាលបរិច្ឆេទផុតកំណត់ ។

២១.២. លិខិតជូនដំណឹងអំពីការកែប្រែ ឬដកយកវិញនូវសំណើដេញថ្លៃ អ្នកដេញថ្លៃត្រូវរៀបចំដាក់ក្នុងស្រោមសំបុត្របិទជិតដែលមានការសម្គាល់ថាការកែប្រែ ឬដកយកវិញ ។

២១.៣.ការដកសំណើដេញថ្លៃក្រោយកាលបរិច្ឆេទផុតកំណត់ទទួលសំណើដេញថ្លៃ និងក្នុងរយៈពេលសុពលភាព ឬក្នុងរយៈពេលពន្យាសុពលភាពនៃឯកសារដេញថ្លៃ បណ្តាលឲ្យមានការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ។ ពុំមានសំណើដេញថ្លៃណាមួយអាចកែប្រែបានទេ បន្ទាប់ពីផុតកាលបរិច្ឆេទនៃការទទួលសំណើដេញថ្លៃ ។

**ប្រការ២២ ៖ ការបើកសំណើដេញថ្លៃ**

២២.១.ស.ភ.ន.វ.ស ត្រូវបើកសំណើដេញថ្លៃ ដោយរួមបញ្ចូលទាំងការកែប្រែ ដែលបានធ្វើនៅចំពោះមុខអ្នកដេញថ្លៃ ឬតំណាងអ្នកដេញថ្លៃដែលចូលរួមតាមពេលវេលា និង ទីកន្លែងដូចមានកំណត់នៅក្នុងឯកសារដេញថ្លៃ ។

២២.២.ស្រោមសំបុត្រដែលមានសម្គាល់ "ការដកយកវិញ" ត្រូវអាន និងប្រកាសជាមុន ។

២២.៣.ឈ្មោះរបស់អ្នកដេញថ្លៃ តម្លៃដាក់ដេញថ្លៃ ការកែប្រែ ការបញ្ចុះតម្លៃនានា និងការដក យកវិញ មាន ឬមិនមានលិខិតប្រាក់កក់ធានាការដេញថ្លៃ ត្រូវបានប្រកាសអាននៅពេលបើកឯកសារ ដេញថ្លៃ ។

២២.៤.សំណើដេញថ្លៃ ដែលមិនបានបើក និងមិនបានប្រកាសអាននៅពេលបើកឯកសារដេញថ្លៃ មិនត្រូវយកមកពិចារណាសម្រាប់ការវាយតម្លៃទេ ។

២២.៥.ស.ភ.ន.វ.ស ត្រូវរៀបចំកំណត់ហេតុនៃការបើកឯកសារដេញថ្លៃ ដោយរួមបញ្ចូលនូវពត៌មានដែល ស.ភ.ន.វ.ស បានប្រកាសនៅពេលបើកសំណើដេញថ្លៃ ។ អ្នកតំណាងដែលបានផ្ទេរសិទ្ធិឲ្យចូលរួមត្រូវចុះឈ្មោះ និងចុះហត្ថលេខាបញ្ជាក់ពីការចូលរួម ។ ក្នុងករណីអ្នកដេញថ្លៃ ឬតំណាងអវត្តមាន នោះជាសិទ្ធិរបស់គណៈកម្មាការបើកឯកសារដេញថ្លៃ និងមិនទទួលខុសត្រូវលើចំនុចខ្វះខាតនៃអ្នកអវត្តមានឡើយ ។

**ប្រការ២៣ ៖ នីតិវិធីនៃការដេញថ្លៃ**

២៣.១.មុននឹងប្រកាសតម្លៃដាក់ដេញថ្លៃរបស់អ្នកដេញថ្លៃនីមួយៗ គណៈកម្មាធិការលទ្ធកម្មត្រូវធ្វើការពិនិត្យ លើឯកសារដេញថ្លៃរបស់អ្នកដេញថ្លៃនីមួយៗ។ ប្រសិនបើពិនិត្យឃើញថា ឯកសារដេញថ្លៃណាមិនបានភ្ជាប់ ឬភ្ជាប់មិនគ្រប់គ្រាន់ មកជាមួយនូវឯកសារដូចមានចែងក្នុងប្រការ៧ គណៈកម្មធិការលទ្ធកម្ម

មានសិទ្ធិបដិសេធឯកសារដេញថ្លៃនោះ។

**២៣.២.**ការដេញថ្លៃតម្លៃដេញថ្លៃអប្បរមា ស្មើនឹងទឹកប្រាក់ចំនួន **២០ ០០០ ០០០៛** (ម្ភៃលាន រៀល) ។ សំណើដេញថ្លៃណា ដែលបានដាក់តម្លៃដេញថ្លៃក្រោមកម្រិតអប្បរមានឹងត្រូវអស់សិទ្ធិចូលរួមដេញថ្លៃ ក្នុងជុំបន្ទាប់ទៀត។

**២៣.៣.**ការដេញថ្លៃផ្គត់ផ្គង់សេវាកម្មផ្ញើកង់ ម៉ូតូ និងរថយន្តនេះ ត្រូវធ្វើឡើងជា ៣ (បី) ជុំ។

**២៣.៤.**ការដេញថ្លៃជុំទីមួយ អ្នកដេញថ្លៃត្រូវដាក់តម្លៃដេញថ្លៃតិចបំផុត ១០ (ដប់) ភាគរយ នៃតម្លៃដេញថ្លៃគោល។

**២៣.៥.**ការដេញថ្លៃជុំទីពីរ អ្នកដេញថ្លៃត្រូវដាក់តម្លៃដេញថ្លៃតិចបំផុត ១០ (ដប់) ភាគរយ នៃតម្លៃដេញថ្លៃជុំទីមួយដែលខ្ពស់ជាងគេ។

**២៣.៦.**ការដេញថ្លៃជុំទីបី អ្នកដេញថ្លៃត្រូវដាក់តម្លៃដេញថ្លៃតិចបំផុត ១០ (ដប់) ភាគរយ នៃតម្លៃដេញថ្លៃជុំទីពីរដែលខ្ពស់ជាងគេ។

**២៣.៧.**ក្នុងករណីដែលអ្នកដេញថ្លៃណាមួយ បានដាក់តម្លៃដេញថ្លៃក្រោមកម្រិតដូចបានកំណត់ ខាងលើនឹងត្រូវបាត់បង់សិទ្ធិក្នុងការដាក់ដេញថ្លៃនៅជុំបន្តបន្ទាប់។

**២៣.៨.**ក្នុងករណីដែលអ្នកដេញថ្លៃសល់តែម្នាក់ ហើយនីតិវិធីមិនទាន់បញ្ចប់ នោះប្រការ ២៣ ត្រូវយកមកអនុវត្តបន្តទៅតាមចំនួនជុំដែលនៅសល់។

**២៣.៩.**ក្នុងករណីតម្លៃដេញថ្លៃស្មើគ្នានៅជុំចុងក្រោយ ការដេញថ្លៃត្រូវបន្តនៅជុំបន្ថែម។ ការដេញថ្លៃនៅជុំបន្ថែមនេះ មិនមានកំណត់កម្រិតភាគរយបន្ថែមទេ ប៉ុន្តែមិនត្រូវមានកម្រិតទាបជាងតម្លៃដេញថ្លៃជុំចុងក្រោយឡើយ។

**ប្រការ២៤ ៖ ដំណើរការជាការសំងាត់**

គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា និងអង្គភាពលទ្ធកម្ម នៃ ស.ភ.ន.វ.ស មិនត្រូវផ្តល់ពត៌មានទាក់ទិននឹងការពិនិត្យ ការបញ្ជាក់អះអាង ការវាយតម្លៃ និង ការប្រៀបធៀបសំណើដេញថ្លៃ និង ការផ្តល់អនុសាសន៍សម្រាប់ការសម្រេចប្រគល់កិច្ចសន្យាដល់អ្នកដេញថ្លៃ ឬបុគ្គលដទៃទៀតដែលមិនមានការពាក់ព័ន្ធជាផ្លូវការនឹងដំណើការនោះទេ រហូតដល់ពេលសម្រេចប្រគល់កិច្ចសន្យាឲ្យអ្នកដេញថ្លៃឈ្នះត្រូវបានប្រកាស។

**ប្រការ២៥ ៖ ការបញ្ជាក់ការអះអាងពីសំណើដេញថ្លៃ**

**២៥.១.**ស.ភ.ន.វ.ស អាចសុំឲ្យអ្នកដេញថ្លៃណាមួយធ្វើការបញ្ជាក់អះអាងពីសំណើដេញថ្លៃរបស់ខ្លួនដើម្បីជួយសម្រួលដល់ការពិនិត្យ ការវាយតម្លៃ និងការប្រៀបធៀបសំណើដេញថ្លៃ ។

**២៥.២.**ការស្នើឲ្យមានការបញ្ជាក់អះអាង និង ការឆ្លើយតបត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ។ ប៉ុន្តែ

មិនមានការ កែប្រែណាមួយក្នុងតម្លៃ ឬខ្លឹមសារនៃសំណើដេញថ្លៃត្រូវបានអនុញ្ញាតឲ្យធ្វើនោះទេ លើកលែងតែការចាំបាច់ក្នុងការកែតម្រូវការភ័ន្តច្រឡំក្នុងការគណនាដែល ស.ភ.ន.វ.ស បានរកឃើញនៅក្នុងការវាយតម្លៃសំណើដេញថ្លៃ ។

**ប្រការ២៦ ៖ ការពិនិត្យបឋមលើសំណើដេញថ្លៃ**

**២៦.១.**ស.ភ.ន.វ.ស ត្រូវធ្វើការពិនិត្យសំណើដេញថ្លៃតាមចំនុចដូចខាងក្រោម៖

**ក.**ភាពពេញលេញនៃឯកសារដេញថ្លៃ

**ខ.**ការគណនាតម្លៃ

**គ.**ការចុះហត្ថលេខា និងប្រថាប់ត្រាលើឯកសារដេញថ្លៃ

**ឃ.**លំដាប់លំដោយនៃឯកសារដេញថ្លៃ

**២៦.២.**សំណើដេញថ្លៃដែលបានដាក់មកនឹងត្រូវបដិសេដចោល ប្រសិនបើពុំឃើញមានឯកសារ ឬពត៌មានដូចខាងក្រោម ៖

**ក.**ពាក្យសុំដេញថ្លៃដែលបានចុះហត្ថលេខា (ជាច្បាប់ដើម)។

**ខ.**ប្រាក់កក់ធានាការដេញថ្លៃ ឬលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ។

**គ.**លិខិតផ្ទេរសិទ្ធិ ក្នុងករណីអ្នកចូលរួមដេញថ្លៃមិនមែនជាប្រធានក្រុមហ៊ុន។

**ឃ.**ប្រសិនបើសំណើដេញថ្លៃមិនបានឆ្លើយតបច្រើនតាមតម្រូវការនោះទេ ស.ភ.ន.វ.ស ត្រូវ បដិសេដចោលសំណើដេញថ្លៃនោះ ។

**២៦.៤.**សំណើដេញថ្លៃដែលឆ្លើយតបច្រើនតាមតម្រូវការ នោះគឺជាសំណើដេញថ្លៃដែលអនុលោម តាមរាល់លក្ខខណ្ឌ និងបច្ចេកទេសនៃសេវាកម្ម នៃឯកសារដេញថ្លៃដោយមិនមានការកែតម្រូវដែលនាំឲ្យ ៖

**ក.**ប៉ះពាល់ធ្ងន់ធ្ងរដល់ទំហំ គុណភាព ឬការអនុវត្តកិច្ចសន្យា។

**ខ.**ដាក់កំហិតខ្លាំងលើសិទ្ធិរបស់ ស.ភ.ន.វ.ស ឬកាតព្វកិច្ចអ្នកដេញថ្លៃនៅក្រោមកិច្ចសន្យា។

**គ.**ប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពប្រកួតប្រជែងរបស់អ្នកដេញថ្លៃផ្សេងទៀត ដែលបានដាក់សំណើដេញថ្លៃឆ្លើយតបច្រើន។

**ប្រការ២៧ ៖ ការកែតម្រូវការភ័ន្តច្រឡំ និងការភ្លេចភ្លាំង**

**២៧.១.**ប្រសិនបើខុសគ្នារវាងអក្សរ និងតួលេខ ចំនួនទឹកប្រាក់សរសេរជាអក្សរត្រូវយកជាផ្លូវការ ។

**២៧.២.**អ្នកដេញថ្លៃត្រូវធ្វើការកែតម្រូវការភន្ត័ច្រឡំ នូវចំណុចផ្សេងៗតាមការចង្អុលបង្ហាញពី ស.ភ.ន.វ.ស បើមិនដូចនេះទេ សំណើដេញថ្លៃត្រូវបដិសេដចោល ហើយប្រាក់កក់ធានាការដេញថ្លៃចំនួន ២% ត្រូវរឹបអូសចូលក្នុងថវិការបស់ ស.ភ.ន.វ.ស ។

**ប្រការ២៨ ៖ សិទ្ធិរបស់ ស.ភ.ន.វ.ស ក្នុងការទទួលយក ឬបដិសេធសំណើដេញថ្លៃ**

ស.ភ.ន.វ.ស រក្សាសិទ្ធិក្នុងការទទួលយក ឬបដិសេធចោល ឬទុកជាមោឃៈនូវសំណើដេញថ្លៃណាមួយ។

ស.ភ.ន.វ.ស អាចបដិសេធសំណើដេញថ្លៃទាំងអស់នៅពេលណាក៏បាន មុននឹងការសំរេចប្រគល់កិច្ចសន្យា ដោយពុំមានកើតឡើងនូវសំណងណាមួយ ចំពោះអ្នកដេញថ្លៃណាមួយដែលទទួល ផលប៉ះពាល់នោះទេ ។

**ប្រការ២៩ ៖ លក្ខណៈវិនិច្ឆ័យនៃការប្រគល់កិច្ចសន្យា**

ស.ភ.ន.វ.ស មានសិទ្ធិសំរេចប្រគល់កិច្ចសន្យាទៅឲ្យអ្នកដេញថ្លៃឈ្នះ ក្នុងករណីដែលសំណើដេញថ្លៃរបស់អ្នកដេញថ្លៃ មានលក្ខណសម្បត្តិគ្រប់គ្រាន់ និងមានតម្លៃខ្ពស់ជាងគេ។

**ប្រការ៣០ ៖ ការជូនដំណឹងអំពីការសម្រេចប្រគល់កិច្ចសន្យា និងចុះហត្ថលេខាលើកិច្ចសន្យា**

**៣០.១.**នៅមុនពេលផុតកំណត់រយៈពេលសុពលភាពនៃសំណើដេញថ្លៃ ស.ភ.ន.វ.ស ត្រូវជូនដំណឹងជាលាយលក្ខ័អក្សរទៅអ្នកដេញថ្លៃឈ្នះ ថាសំណើដេញថ្លៃនោះត្រូវបានទទួលយក ។ លិខិតជូនដំណឹងនេះត្រូវប្រគល់ដោយផ្ទាល់ ឬដោយទូរសារ ។

**៣០.២.**នៅពេលជូនដំណឹងអំពីការសម្រេចប្រគល់កិច្ចសន្យា ស.ភ.ន.វ.ស ត្រូវផ្ញើឲ្យអ្នកដេញថ្លៃឈ្នះនូវទម្រង់កិច្ចសន្យា ដែលមាននៅក្នុងឯកសារដេញថ្លៃ ដោយរួមបញ្ចូលកិច្ចព្រមព្រៀងទាំងអស់រវាងភាគីទាំងពីរ ។

**៣០.៣.**ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីបានទទួលទម្រង់កិច្ចសន្យា អ្នកដេញថ្លៃឈ្នះត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើកិច្ចសន្យានេះ ហើយបញ្ជូនត្រឡប់មក ស.ភ.ន.វ.ស វិញ។ បើមិនដូចនេះទេ ស.ភ.ន.វ.ស មានសិទ្ធិលុបចោលលទ្ធផលដេញថ្លៃ និងប្រគល់កិច្ចសន្យាឲ្យក្រុមហ៊ុនផ្សេង ហើយអ្នកដេញថ្លៃឈ្នះនឹងត្រូវបាត់សិទ្ធិក្នុងការចូលរួមដេញថ្លៃជាសាធារណៈនៅ ស.ភ.ន.វ.ស ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ឆ្នាំ និងប្រាក់កក់ធានាការដេញថ្លៃត្រូវបានរឹបអូស ។

**ប្រការ៣១ ៖ ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**

**៣១.១.**នៅក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការសម្រេចប្រគល់កិច្ចសន្យា អ្នកដេញថ្លៃឈ្នះត្រូវផ្តល់ជូន ស.ភ.ន.វ.ស នូវលិខិតធានាប្រាក់កក់ ធានាការអនុវត្តកិច្ចសន្យា ដែលមានចំនួនទឹកប្រាក់ស្មើ ពីរខែនៃតម្លៃកិច្ចសន្យា ដែលចេញដោយធនាគារជាតិនៃកម្ពុជា ឬធនាគារជាតិ ឬធនាគារដែលបានចុះអនុសារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**៣១.២.**ការខកខានរបស់អ្នកដេញថ្លៃឈ្នះ ក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការលុបចោលការប្រគល់កិច្ចសន្យា និងរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ។ លើសពីនេះទៀត ត្រូវបាត់សិទ្ធិក្នុងការចូលរួមដេញថ្លៃជាសាធារណៈនៅ ស.ភ.ន.វ.ស ក្នុងរយៈពេលយ៉ាងតិច ៣ (បី) ឆ្នាំ ។

**៣១.៣.**បន្ទាប់ពីទទួលបានលិខិតធានាប្រាក់កក់ ធានាការអនុវត្តកិច្ចសន្យា ស.ភ.ន.វ.ស ត្រូវជូនដំណឹងទៅដល់អ្នកដេញថ្លៃដទៃទៀតអំពីលទ្ធផលនៃការដេញថ្លៃនេះ ។

៣១.៤.ប្រាក់កក់ធានាការអនុវត្តនេះ ត្រូវបង្វែរជូនអ្នកផ្គត់ផ្គង់វិញ បន្ទាប់ពីបញ្ចប់កិច្ចសន្យា ។

៣១.៥.ករណីអ្នកផ្គត់ផ្គង់បោះបង់ ឬ មិនអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់នេះត្រូវរឹបអូសចូលថវិកា ស.ភ.ន.វ.ស ។

**ប្រការ៣២ ៖ ការចូលជាធរមាននៃកិច្ចសន្យា**

កិច្ចសន្យាចូលជាធរមាន ដោយគិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើកិច្ចសន្យា ដោយ ស.ភ.ន.វ.ស និងអ្នកដេញថ្លៃឈ្នះ ។

**ប្រការ៣៣ ៖ ការសាកសួរព័ត៌មាន**

ក្នុងរយៈពេល ១៤ថ្ងៃ បន្ទាប់ពីការសម្រេចប្រគល់កិច្ចសន្យាត្រូវបានប្រកាស អ្នកដេញថ្លៃចាញ់មានសិទ្ធិស្នើសុំឲ្យមានការពន្យល់ ដើម្បីបានដឹងច្បាស់ពីមូលហេតុនៃការបរាជ័យនៃសំណើដេញថ្លៃរបស់ខ្លួន ហើយគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា (គ.ប.វ.ប) មានកាតព្វកិច្ចផ្តល់ការពន្យល់នេះ ។

**ប្រការ៣៤ ៖ បណ្តឹងតវ៉ា**

៣៤.១.ការតវ៉ាអាចធ្វើឡើងដោយភាគីណាមួយ នៅក្នុងដំណាក់កាលនៃដំណើរកិច្ចលទ្ធកម្ម ហើយ គ.ប.វ.ប នឹងឆ្លើយតបបន្ទាប់ពីការវាយតម្លៃត្រូវបានបញ្ចប់ ។

៣៤.២.បណ្តឹងតវ៉ាត្រូវផ្ញើទៅ ស.ភ.ន.វ.ស ដូចមានឈ្មោះ និងអាស័យដ្ឋាននៅក្នុងឯកសារដេញថ្លៃ។ ស.ភ.ន.វ.ស នឹងធ្វើការអង្កេតលើមូលដ្ឋាននៃការតវ៉ា និងធ្វើការឆ្លើយតបជាលាយល័ក្ខណ៍អក្សរក្នុងរយៈពេល ១៤ថ្ងៃ ប្រតិទិន ចាប់ពីការវាយតំលៃបានបញ្ចប់ ។

**ប្រការ៣៥ ៖ ការដោះស្រាយវិវាទ**

ក្នុងករណីមានវិវាទកើតឡើងរវាង ស.ភ.ន.វ.ស និងអ្នកផ្គត់ផ្គង់អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ឬ ទាក់ទិននឹងការគោរពតាមកិច្ចសន្យា ត្រូវដោះស្រាយតាមរយៈការចរចាជាមុនសិនរវាងភាគីទាំងពីរ។ ប្រសិនបើបរាជ័យ នោះភាគីទាំងពីរត្រូវដោះស្រាយតាមរយៈមេធាវី ។ ប្រសិនបើវិវាទត្រូវដោះស្រាយដោយមេធាវី ភាគីទាំងពីរមានសិទ្ធិជ្រើសរើសមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្តាលមួយរូបនឹងត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របទៅលើការតែងតាំងអាជ្ញាកណ្តាល ឬអាជ្ញាកណ្តាលមិនអាចដោះស្រាយវិវាទបានទេនោះ ត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី២

## លក្ខខណ្ឌទូទៅនៃកិច្ចសន្យា

**ប្រការ៣៦ ៖ និយមន័យ**

ពាក្យបច្ចេកទេសត្រូវបានកំណត់ន័យដូចខាងក្រោម ៖

**-កិច្ចសន្យា៖** សំដៅដល់កិច្ចព្រមព្រៀងដែលធ្វើឡើងរវាង ស.ភ.ន.វ.ស និងអ្នកផ្គត់ផ្គង់ ដូចមានចែងក្នុងទម្រង់កិច្ចសន្យា ចុះហត្ថលេខាដោយភាគីទាំងសងខាង ដោយរួមបញ្ចូលឯកសារភ្ជាប់ និងឧបសម្ព័ន្ធទាំងអស់ ។

**-តម្លៃកិច្ចសន្យា៖** សំដៅដល់ចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ បានដាក់នាពេលដេញថ្លៃ និងត្រូវទូទាត់ទៅឲ្យ ស.ភ.ន.វ.ស ជារៀងរាល់ខែ នៅក្នុងរយៈពេលអនុវត្តកិច្ចសន្យា ។

**-អ្នកទទួលសេវាកម្ម៖** សំដៅដល់ ស.ភ.ន.វ.ស ដែលទទួលយកសេវាកម្ម ។

**-អ្នកផ្គត់ផ្គង់៖** សំដៅដល់បុគ្គល ឬក្រុមហ៊ុនដែលផ្តល់សេវាកម្មនៅក្នុងកិច្ចសន្យា។

**-សេវាកម្ម៖** សំដៅដល់សេវាកម្មទាំងអស់ដែលអ្នកផ្គត់ផ្គង់ត្រូវផ្តល់ទៅឲ្យ ស.ភ.ន.វ.ស ក្នុងការធ្វើអាជីវកម្មផ្ញើកង់ ម៉ូតូ និងរថយន្ត របស់និស្សិត បុគ្គលិក និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យ នៅក្នុងកិច្ចសន្យា ។

**-ទីតាំងគម្រោង៖** សំដៅដល់បរិវេណ ស.ភ.ន.វ.ស ដែលជាទីតាំងអនុវត្តកិច្ចសន្យា។

-ថ្ងៃ៖ សំដៅដល់ថ្ងៃប្រតិទិនសុរិយគតិ ។

## ប្រការ៣៧ ៖ ការអនុវត្ត

លក្ខខណ្ឌទូទៅ ត្រូវយកមកអនុវត្តក្រោមទម្រង់នៃកិច្ចសន្យានេះដោយមិនផ្លាស់ប្តូរ តាមលក្ខខណ្ឌនៃផ្នែកដទៃទៀតនៃកិច្ចសន្យា ។

## ប្រការ៣៨ ៖ សវនកម្ម និងអធិការកិច្ច

អ្នកផ្គត់ផ្គង់ ត្រូវអនុញ្ញាតឲ្យ ស.ភ.ន.វ.ស ឬទីភ្នាក់ងារផ្តល់មូលនិធិ ធ្វើអធិការកិច្ចលើបញ្ជីគណនេយ្យ និងលិខិតស្នាមទាំងអស់របស់ អ្នកផ្គត់ផ្គង់ ដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យា និងឲ្យមានការធ្វើសវនកម្មលើបញ្ជីគណនេយ្យ និងលិខិតស្នាមទាំងនោះ ដោយសវនករដែលតែងតាំងដោយ ស.ភ.ន. វ.ស ឬទីភ្នាក់ងារផ្តល់មូលនិធិ ។

## ប្រការ៣៩ ៖ ភាសា

កិច្ចសន្យាត្រូវធ្វើឡើងជាភាសាខ្មែរ ។ កិច្ចសន្យាណាដែលរៀបចំជាភាសាបរទេស ត្រូវបកប្រែជាភាសាខ្មែរ។ ក្នុងករណីដែលមានភាពមិនស្របគ្នារវាងភាសាខ្មែរ និងភាសាបរទេស នោះឯកសារដែលសរសេរជាភាសាខ្មែរ ជាឯកសារផ្លូវការ ។

## ប្រការ៤០ ៖ ក្រុមហ៊ុនរួមទុន

ប្រសិនបើអ្នកផ្គត់ផ្គង់ជាក្រុមហ៊ុនរួមទុន ក្រុមហ៊ុនពហុសាសន៍ ឬជាសមាគម រាល់សមាជិកទាំងអស់ត្រូវទទួលខុសត្រូវរួមគ្នាចំពោះ ស.ភ.ន.វ.ស ក្នុងការបំពេញតាមលក្ខខណ្ឌនៃកិច្ចសន្យា និងត្រូវតែងតាំងសមាជិកណាមួយជាអ្នកដឹកនាំដោយមានសិទ្ធិភ្ជាប់កាតព្វកិច្ចរបស់ក្រុមហ៊ុនរួមទុន ក្រុមហ៊ុនពហុសាសន៍ ឬសមាគមនោះ ។

**ប្រការ៤១ ៖ ម៉ោងដែលត្រូវផ្តល់សេវាកម្មប្រចាំថ្ងៃ**

អ្នកផ្គត់ផ្គង់ត្រូវរៀបចំបុគ្គលិក និង សម្ភារៈផ្សេងៗដើម្បីផ្តល់សេវាកម្មជូន ស.ភ.ន.វ.ស អោយបាន មុនម៉ោង ៦ (ប្រាំមួយ) ព្រឹក ជារៀងរាល់ថ្ងៃ និងបញ្ចប់ការផ្តល់សេវាកម្មនៅត្រឹមម៉ោង ២២ (ម្ភៃពីរ) ជាកំហិត។ ក្នុងករណីដែលកង់ ម៉ូតូ និងរថយន្តទាំងអស់ ដែលទទួលសេវាកម្មមិនទាន់ចាកចេញ អស់ពីបរិវេណនៃសាកលវិទ្យាល័យ ទៅតាមម៉ោងដែលបានកំណត់ នោះអ្នកផ្គត់ផ្គង់ត្រូវចាត់វិធានការដោះស្រាយ និងទទួលខុសត្រូវលើការបាត់បង់ និងការខូចខាតផ្សេងទៀតដោយខ្លួនឯង។

**ប្រការ៤២ ៖ តម្លៃនៃសេវាកម្មផ្ញើកង់ ម៉ូតូ និងរថយន្ត**

អ្នកផ្គត់ផ្គង់ ត្រូវផ្តល់សេវាកម្មផ្ញើកង់ ម៉ូតូ និងរថយន្ត ក្នុងបរិវេណនៃសាកលវិទ្យាល័យ ដោយយកតម្លៃត្រឹមកម្រិតដូចខាងក្រោម ៖

៤២.១.សម្រាប់រាល់និស្សិត និងភ្ញៀវ

| | |
|---|---|
| ក.មិនយកតម្លៃ | ចំពោះកង់ |
| ខ.តម្លៃ ៣០០៛ (បីរយ រៀល) | ចំពោះម៉ូតូមួយគ្រឿង |
| គ.តម្លៃ ១០០០៛ (មួយពាន់ រៀល) | ចំពោះរថយន្តមួយគ្រឿង |

៤២.២.សម្រាប់សាស្ត្រាចារ្យ សាស្ត្រាចារ្យវេលាការ និងបុគ្គលិក ស.ភ.ន.វ.ស

កង់ ម៉ូតូ និងរថយន្ត របស់សាស្ត្រាចារ្យ សាស្ត្រាចារ្យវេលាការ និងបុគ្គលិករបស់ ស.ភ.ន.វ.ស ទាំងអស់ អ្នកផ្គត់ផ្គង់ត្រូវផ្តល់សេវាកម្មដោយឥតគិតថ្លៃ ក្នុងករណីសាស្ត្រាចារ្យ សាស្ត្រាចារ្យវេលាការ និងបុគ្គលិកនោះ មានបណ្ណបញ្ជាក់ត្រឹមត្រូវ និងបានដាក់ត្រឹមត្រូវតាមទីតាំងកំណត់ដោយ ស.ភ.ន.វ.ស ។

**ប្រការ៤៣ ៖ រយៈពេលអនុវត្តកិច្ចសន្យា**

អ្នកផ្គត់ផ្គង់ ត្រូវធ្វើការផ្តល់សេវាកម្មជូន ស.ភ.ន.វ.ស ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចុះកិច្ចសន្យា ។ ក្រោយពេលបញ្ចប់រយៈពេល ០២ (ពីរ) ឆ្នាំនេះ កិច្ចសន្យានឹងអស់សុពលភាពដោយស្វ័យប្រវត្តិ ។

**ប្រការ៤៤៖ ការធានា និងការទទួលខុសត្រូវរបស់អ្នកផ្គត់ផ្គង់**

អ្នកផ្គត់ផ្គង់ ត្រូវធានា និងទទួលខុសត្រូវដូចខាងក្រោម ៖

ក.រៀបចំទុកដាក់ផ្ញើកង់ ម៉ូតូ និងរថយន្ត ទៅតាមកន្លែងដែលកំណត់ដោយ ស.ភ.ន.វ.ស ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ។

ខ.ធានារក្សាសណ្តាប់ធ្នាប់ និងចរាចរណ៍ចេញ - ចូលរបស់និស្សិត សាស្ត្រាចារ្យគ្រប់ម៉ោងសិក្សាឲ្យបានល្អ ចៀសវាងការកកស្ទះរំខានដល់ពេលវេលាសិក្សារបស់និស្សិត និងអ្នកដំណើរលើផ្លូវសាធារណៈ។

គ.ទទួលខុសត្រូវរាល់ការខូចខាតទាំងឡាយ ដែលបង្កឡើងដោយបុគ្គលិករបស់អ្នកផ្គត់ផ្គង់ចំពោះស.ភ.ន.វ.ស និស្សិត សាស្ត្រាចារ្យ បុគ្គលិក ភ្ញៀវ និងសាស្ត្រាចារ្យវេលាការរបស់ ស.ភ.ន.វ.ស ។

ឃ.ទទួលខុសត្រូវរាល់ការខូចខាត ឬបាត់បង់ កង់ ម៉ូតូ រថយន្ត និងសម្ភារៈផ្សេងទៀតដែលជាផ្នែក ឬជាប់ជាមួយនឹងកង់ ម៉ូតូ រថយន្ត របស់និស្សិត សាស្ត្រាចារ្យ បុគ្គលិក ភ្ញៀវ និង សាស្ត្រាចារ្យវេលាការរបស់ ស.ភ.ន.វ.ស ដែលទទួលសេវាកម្ម ។

ង.ដោះស្រាយរាល់ករណីមានវិវាទក្នុងអាជីវកម្មរបស់អ្នកផ្គត់ផ្គង់ និងរាល់ចំណាយ ជាបន្ទុករបស់អ្នកផ្គត់ផ្គង់។

ច.នៅពេលការផ្តល់សេវាកម្មជាប្រចាំថ្ងៃបានបញ្ចប់ ស.ភ.ន.វ.ស មិនអនុញ្ញាតឲ្យបុគ្គលិករបស់អ្នកផ្គត់ផ្គង់ណាម្នាក់ ស្នាក់នៅក្នុងបរិវេណនៃសាកលវិទ្យាល័យឡើយ ។

ឆ.អ្នកផ្គត់ផ្គង់ ត្រូវដាក់តម្លៃសេវាកម្មរបស់ខ្លួន នៅលើបង្កាន់ដៃផ្ញើកង់ ម៉ូតូ និងរថយន្តទៅតាមការកំណត់របស់ ស.ភ.ន.វ.ស ។

ឈ.អ្នកផ្គត់ផ្គង់ត្រូវរៀបចំបុគ្គលិករបស់ខ្លួន ឲ្យពាក់នូវឯកសណ្ឋានឲ្យបានត្រឹមត្រូវ ដោយនៅលើឯកសណ្ឋាននោះត្រូវដាក់ឈ្មោះអាជីវកម្មរបស់អ្នកផ្គត់ផ្គង់។

**ប្រការ៤៥ ៖ ការជូនដំណឹង**

៤៥.១.ការជូនដំណឹងនានា ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។

៤៥.២.ការជូនដំណឹងនានាដោយភាគីនៃកិច្ចសន្យា ត្រូវចាត់ទុកជាបានការ បន្ទាប់ពីភាគីម្ខាងទៀតទទួលបានការជូនដំណឹងនោះ ។

**ប្រការ៤៦ ៖ ច្បាប់កំពុងអនុវត្ត**

កិច្ចសន្យា ត្រូវអនុវត្ត និងបកស្រាយ ដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៧៖ ការដោះស្រាយវិវាទ**

៤៧.១.វិវាទណាមួយដែលកើតឡើងរវាង ស.ភ.ន.វ.ស និងអ្នកផ្គត់ផ្គង់ ពាក់ពន្ធ័លក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ឬទាក់ទិននឹងការមិនគោរពតាមកិច្ចសន្យា ត្រូវដោះស្រាយតាមរយៈការចរចាជាមុនសិនរវាងភាគីទាំងពីរ ។

៤៧.២.ប្រសិនបើការចរចាបរាជ័យ នោះភាគីទាំងពីរត្រូវដោះស្រាយតាមរយៈមេធាវី ។ ក្នុងករណី នេះភាគីទាំងពីរមានសិទ្ធិជ្រើសរើសមេធាវីម្នាក់មួយរូប ហើយអាជ្ញាកណ្តាលមួយរូប នឹងត្រូវតែងតាំងដោយមានការយល់ព្រមពីភាគីទាំងពីរ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របទៅលើការតែងតាំងអាជ្ញាកណ្តាល ឬ អាជ្ញាកណ្តាលមិនអាចដោះស្រាយវិវាទបានទេ នោះត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

៤៧.៣.ក្នុងករណីដែលមានរឿងក្តីកើតឡើងបណ្តាលមកពី ភាគីណាមួយរំលោភលើលក្ខខណ្ឌនានានៃកិច្ចសន្យា ភាគីនោះត្រូវទទួលខុសត្រូវលើរាល់ការចំណាយនានា ក្នុងដំណើរការរឿងក្តី ។

**ប្រការ៤៨ ៖ ការផ្តល់សេវាកម្ម**

អ្នកផ្គត់ផ្គង់ ត្រូវផ្តល់សេវាកម្មជូន ស.ភ.ន.វ.ស ចាប់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ ជាកំហិត ។

**ប្រការ៤៩ ៖ តម្លៃនៃកិច្ចសន្យា**

៤៩.១.តម្លៃកិច្ចសន្យា ដែលអ្នកផ្គត់ផ្គង់ទទួលសិទ្ធិក្នុងការផ្តល់សេវាកម្ម ដែលបានផ្តល់តាមកិច្ចសន្យា មិនត្រូវខុសពីចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់បានឈ្នះ នៅក្នុងនីតិវិធីនៃការដេញថ្លៃឡើយ លើកលែងតែករណីមានការកែតម្រូវតម្លៃតាមសំណើរបស់ ស.ភ.ន.វ.ស ។

៤៩.២.ចំនួនទឹកប្រាក់ ដែលអ្នកផ្គត់ផ្គង់បានឈ្នះក្នុងការដេញថ្លៃ គឺជាតម្លៃនៃកិច្ចសន្យា ក្នុង ១ (មួយ) ខែ ។

**ប្រការ៥០ ៖ ការទូទាត់**

៥០.១.អ្នកផ្គត់ផ្គង់ត្រូវធ្វើការទូទាត់តម្លៃកិច្ចសន្យាជូន ស.ភ.ន.វ.ស ចំនួន១០ (ដប់) ខែ និងលើកលែងការទូទាត់ចំនួន ០២ (ពីរ) ខែ ក្នុងមួយឆ្នាំសិក្សា។ ខែដែលលើកលែងការទូទាត់នោះ គឺខែមេសា និងខែកញ្ញា។

៥០.២.ការទូទាត់ត្រូវធ្វើឡើងជារៀងរាល់ខែ យ៉ាងយូរត្រឹមថ្ងៃទី០៥ នៃខែបន្ទាប់ជាកំហិត បើមិនដូច្នេះទេនឹងត្រូវពិន័យជាប្រាក់ចំនួន ១ (មួយ) ភាគរយក្នុងមួយថ្ងៃ នៃទឹកប្រាក់ដែលត្រូវបង់ជូន ស.ភ.ន.វ.ស ក្នុងមួយខែ។

៥០.៣.ក្នុងករណីដែលអ្នកផ្គត់ផ្គង់ ខកខានមិនបានបង់ប្រាក់ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ចាប់ពីថ្ងៃពិន័យនោះ ស.ភ.ន.វ.ស មានសិទ្ធិបញ្ចប់កិច្ចសន្យាជាឯកតោភាគី ។

**ប្រការ៥១ ៖ ការបង់ពន្ធ និងអាករ**

អ្នកផ្គត់ផ្គង់ មានកាតព្វកិច្ចបង់ពន្ធ និងអាករគ្រប់ប្រភេទជូនរដ្ឋ តាមច្បាប់ និងលិខិតគតិយុត្តជាធរមាន។

**ប្រការ៥២ ៖ ការអនុញ្ញាត ការអនុម័តយល់ព្រម និងអាជ្ញាប័ណ្ណ**

នៅពេលផ្គត់ផ្គង់សេវាកម្ម អ្នកផ្គត់ផ្គង់ត្រូវមានការអនុញ្ញាត និងមានអាជ្ញាប័ណ្ណផ្តល់ដោយអាជ្ញាធរសាធារណៈក្នុងប្រទេស ។

**ប្រការ៥៣ ៖ ប្រាក់កក់ធានាការអនុវត្ត**

៥៣.១.អ្នកផ្គត់ផ្គង់ ត្រូវផ្តល់លិខិតធានា ប្រាក់កក់ធានាការអនុវត្តឲ្យ ស.ភ.ន.វ.ស មិនលើសពីរយៈពេល ០៧(ប្រាំពីរ) ថ្ងៃបន្ទាប់ពីអ្នកផ្គត់ផ្គង់ទទួលបាននូវសេចក្តីជូនដំណឹងអំពីការសំរេចប្រគល់កិច្ចសន្យា ។ លិខិតធានាប្រាក់កក់នេះ មានចំនួនទឹកប្រាក់ស្មើនឹង ពីរខែនៃតម្លៃកិច្ចសន្យា ចេញដោយធនាគារជាតិនៃកម្ពុជា ឬធនាគារជាតិ ឬធនាគារដែលបានចុះអនុសារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៥៣.២.ប្រាក់កក់ធានាការអនុវត្ត ជាប្រាក់សំណងទៅនឹងការខាតបង់ណាមួយ ដែលកើតចេញពីការខកខានរបស់អ្នកផ្គត់ផ្គង់ ក្នុងការបំពេញចប់សព្វគ្រប់នូវកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា ក្នុងករណីធ្ងន់ធ្ងរប្រាក់កក់នេះនឹងត្រូវរឹបអូសទាំងស្រុង។ ការរឹបអូសប្រាក់កក់នេះមិនបណ្តាលឲ្យអ្នកផ្គត់ ផ្គង់រួចផុតពីការបំពេញកាតព្វកិច្ចដែលនៅសេសសល់ និង ការទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ ។

**ប្រការ៥៤ ៖ ការសម្ងាត់**

អ្នកផ្គត់ផ្គង់ មិនត្រូវបង្ហាញព័ត៌មាននៃកិច្ចសន្យា ឬ បទប្បញ្ញត្តិណាមួយ ឬ យថាប្រភេទ ផែនការគំនូសបង្ហាញ គំរូ ឬពត៌មានផ្សេងទៀតឲ្យទៅអ្នកដទៃ ដោយមិនមានការយល់ព្រមជាលាយល័ក្ខណ៍អក្សរជាមុនពី ស.ភ.ន.វ.ស ឡើយ។ ការបង្ហាញព័ត៌មានទៅឲ្យបុគ្គលដែលធ្វើការឲ្យអ្នកផ្គត់ផ្គង់ ត្រូវធ្វើឡើងជាសម្ងាត់ និងក្នុងករណីចាំបាច់សម្រាប់គោលបំណងនៃការអនុវត្តកិច្ចសន្យាតែប៉ុណ្ណោះ ។

**ប្រការ៥៥ ៖ ការចុះកិច្ចសន្យាបន្ត**

អ្នកផ្គត់ផ្គង់ គ្មានសិទ្ធិផ្ទេរផ្នែកខ្លះ ឬទាំងមូលនៃកិច្ចសន្យាទៅឲ្យអ្នកផ្គត់ផ្គង់ផ្សេងបន្តឡើយ លើកលែងតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី ស.ភ.ន.វ.ស ។ នៅពេលដែលការចុះកិច្ចសន្យាបន្តបែបនេះត្រូវបានអនុញ្ញាត អ្នកផ្គត់ផ្គង់ត្រូវទទួលខុសត្រូវចំពោះ ស.ភ.ន.វ.ស ដោយផ្ទាល់នូវរាល់សកម្មភាព និងការខូតខាចផ្សេង ដែលប្រព្រឹត្តដោយអ្នកផ្គត់ផ្គង់បន្តនោះ ។

**ប្រការ៥៦ ៖ ករណីប្រធានស័ក្តិ**

**៥៦.១.**សម្រាប់គោលបំណងនៃប្រការនេះ "ប្រធានស័ក្តិ" មានន័យថាព្រឹត្តិការណ៍ ឬស្ថានភាពដែលមិនអាចស្មានជាមុនបាន មិនអាចជៀសវាងបាន និងហួសពីការគ្រប់គ្រងរបស់អ្នកផ្គត់ផ្គង់។ ព្រឹត្តិការណ៍នោះរួមមាន សង្គ្រាម ការបះបោរ ខ្យល់ព្យុះ ទឹកជំនន់ ជំងឺរាតត្បាត ការដាក់កំហិតតាមផ្លូវច្បាប់ ... ។ល។

**៥៦.២.**ប្រសិនបើការយឺតយ៉ាវ ឬខកខានក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ដែលបណ្តាលពីករណីប្រធានស័ក្តិ អ្នកផ្គត់ផ្គង់មិនត្រូវបានទទួលនូវការរឹបអូស ប្រាក់កក់ធានាការអនុវត្ត ឬសំណង ព្រាងទុកឡើយ ។

**ប្រការ៥៧ ៖ ការបញ្ចប់កិច្ចសន្យាដោយសារកំហុសរបស់អ្នកផ្គត់ផ្គង់**

ស.ភ.ន.វ.ស អាចបញ្ចប់កិច្ចសន្យាទាំងស្រុង ឬ ដោយផ្នែក ដោយធ្វើការជូនដំណឹងជាលាយល័ក្ខអក្សរទៅឲ្យអ្នកផ្គត់ផ្គង់ ក្នុងករណីដូចខាងក្រោម ៖

ក.ប្រសិនបើអ្នកផ្គត់ផ្គង់មិនបានអនុវត្តកាតព្វកិច្ច ដូចមានចែងក្នុងកិច្ចសន្យា

ខ.ប្រសិនបើអ្នកផ្គត់ផ្គង់បានប្រព្រឹត្តអំពើពុករលួយ ឬក្លែងបន្លំ នៅក្នុងការប្រជែង យកកិច្ចសន្យា ឬនៅក្នុងការអនុវត្តកិច្ចសន្យា ។

**ប្រការ៥៨ ៖ ការបញ្ចប់កិច្ចសន្យាដោយសារ ភាពគ្មានប្រាក់សង**

ស.ភ.ន.វ.ស អាចធ្វើការបញ្ចប់កិច្ចសន្យាបានដោយ ជូនដំណឹងជាលាយល័ក្ខអក្សរទៅអ្នកផ្គត់ផ្គង់ ប្រសិនអ្នកផ្គត់ផ្គង់ក្ស័យធន ឬ ភាពគ្មានប្រាក់សង ។ នៅក្នុងករណីនេះ ការបញ្ចប់កិច្ចសន្យាត្រូវធ្វើឡើងដោយពុំមានសំណងចំពោះអ្នកផ្គត់ផ្គង់នោះទេ ។

**ប្រការ៥៩ ៖ ការផ្ទេរ**

អ្នកផ្គត់ផ្គង់មិនត្រូវផ្ទេរទាំងស្រុង ឬផ្នែកខ្លះនៃកាតព្វកិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យានោះទេ លើកលែងតែមានការយល់ព្រមជាលាយល័ក្ខអក្សរជាមុនពី ស.ភ.ន.វ.ស ។

**ប្រការ៦០ ៖ ការប្រើប្រាស់ឯកសារ**

ប្រសិនបើពុំមានការយល់ព្រមពី ស.ភ.ន.វ.ស អ្នកផ្គត់ផ្គង់មិនត្រូវប្រើប្រាស់ឯកសារនៃកិច្ចសន្យា ឬ មិនត្រូវបង្ហាញ ឬផ្តល់ពត៌មានដែលមាននៅក្នុងឯកសារកិច្ចសន្យាឲ្យអ្នកដទៃដឹងឡើយ លើកលែងតែការប្រើប្រាស់ក្នុងគោលបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា។

**ប្រការ៦១ ៖ អវសាន**

ភាគីទាំងពីរ មានកាតព្វកិច្ចអនុវត្តតាមប្រការនីមួយៗ នៃកិច្ចសន្យានេះឲ្យបានម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់។ កិច្ចសន្យានេះត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ។ កិច្ចសន្យានេះត្រូវបានធ្វើឡើងជាភាសាខ្មែរចំនួន ៥ (ប្រាំ) ច្បាប់ដើម និង ត្រូវប្រគល់ជូនដូចខាងក្រោម ៖

| | |
|---|---|
| -អ្នកផ្គត់ផ្គង់ | ចំនួន ១ច្បាប់ |
| -ស.ភ.ន.វ.ស | ចំនួន ៣ច្បាប់ |
| -ឯកសារកាលប្បវត្តិ | ចំនួន ១ច្បាប់ |

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ខែសីហា ឆ្នាំ២០១៥

**ប្រធានអង្គភាពលទ្ធកម្ម**

**បានឃើញ និងឯកភាព**

ប្រធានគណៈកម្មាធិការលទ្ធកម្ម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន រតនាគារជាតិ
លេខ : [illegible] អ.រតន.

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
ចូល
លេខ [illegible]
ថ្ងៃទី [illegible] ម៉ោង [illegible]
បញ្ជូន [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៤

## សូមជម្រាបជូន
## ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**កម្មវត្ថុ÷** ការផ្តល់លេខគណនីសម្រាប់ការបង់ប្រាក់កក់ ទាំងនៅអគ្គនាយកដ្ឋានរតនាគារជាតិ និងនៅរតនាគាររាជធានី ខេត្ត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា÷ ដើម្បីសម្រួលដល់ការបង់ (១) ប្រាក់កក់ធានាការដេញថ្លៃ-២% (២) ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា-១០% និង (៣) ប្រាក់កក់តម្កល់ធានាអាជីវកម្មរយៈពេលវែង អគ្គនាយកដ្ឋានរតនាគារជាតិសូមផ្តល់ជូននូវលេខគណនីសម្រាប់ទទួលការបង់ប្រាក់កក់ដូចខាងក្រោម÷

I. នៅអគ្គនាយកដ្ឋានរតនាគារជាតិ លេខគណនីនៅធនាគារជាតិនៃកម្ពុជា មាន÷

000000013449 ជាប្រាក់រៀល សម្រាប់÷ (១) ប្រាក់កក់ធានាការដេញថ្លៃ-២% (២) ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា-១០% និង (៣) ប្រាក់កក់តម្កល់ធានាអាជីវកម្មរយៈពេលវែង

000000013450 ជាប្រាក់ដុល្លារអាមេរិក សម្រាប់÷ (១) ប្រាក់កក់ធានាការដេញថ្លៃ-២% (២) ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា-១០% និង (៣) ប្រាក់កក់តម្កល់ធានាអាជីវកម្មរយៈពេលវែង

II. នៅរតនាគាររាជធានី ខេត្ត÷ **លេខគណនីជាប្រាក់រៀល** សម្រាប់ប្រាក់កក់ធានាការដេញថ្លៃ-២% និង ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា-១០% មានបើកនៅសាខាធនាគារកាណាឌីយ៉ា ក.អ និងនៅសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ដូចខាងក្រោម÷

| | | ប្រាក់កក់ ១០% ជាប្រាក់រៀល | | ប្រាក់កក់ ២% ជាប្រាក់រៀល | |
|---|---|---|---|---|---|
| ល.រ | រតនាគារ | CANADIA | ACLEDA | CANADIA | ACLEDA |
| 01. | រាជធានី ភ្នំពេញ | 001-0001-494867 | 0001-01573746-16 | 001-0002-376526 | N/A |
| 02 | ខេត្ត កណ្តាល | 014-0000-055944 | 2400-01569277-17 | 014-0000-065311 | N/A |
| 03 | ខេត្ត កំពង់ចាម | 005-0000-071762 | 1000-10848444-14 | 005-0000-080818 | N/A |
| 04 | ខេត្ត បាត់ដំបង | 004-0000-107966 | 3476-01533226-26 | 004-0000-318584 | N/A |
| 05 | ខេត្ត សៀមរាប | 008-0000-138146 | 3475-01566001-11 | 008-0000-301756 | N/A |




| | | |
|---|---|---|
| បានឃើញនិង ឯកភាព | បានពិនិត្យត្រឹមត្រូវ | ភ្នំពេញថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ |
| ប្រធានគណកម្មាធិការ គបរស | ប្រធានអង្គភាពលទ្ធកម្ម | អ្នកគូរប្លង់ |